**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ៤៥៥១ មស.សជណ

ថ្ងៃ ចន្ទ ១០ រោច ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

**យោង** ៖- លិខិតលេខ១០៩៧ មស.ក្រខ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ
- ប្រកាសលេខ៣១៤១ មស.ប្រក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ
- សេចក្តីជូនដំណឹងលេខ៣៣៣៦ មស.សជណ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ។

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សូមជូនដំណឹងដល់ បេក្ខជនដែលបានបំពេញបែបបទសុំសិទ្ធិប្រឡងចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័នទាំង៤ ខាងលើ ឱ្យបានជ្រាបថា៖

១. គណៈកម្មការរៀបចំការប្រឡង នឹងបិទផ្សាយបញ្ជីឈ្មោះបេក្ខជន នៅក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីទុកសិទ្ធិឱ្យបេក្ខជនធ្វើការតវ៉ាក្នុងករណី ដែលមិនមានឈ្មោះប្រឡង ខុសថ្ងៃខែឆ្នាំកំណើត ឬបញ្ហាផ្សេងៗ មកអនុគណៈកម្មការទទួលពាក្យនិងរៀបចំឯកសារ នៅក្រសួងមុខងារសាធារណៈ **ចាប់ពីថ្ងៃពុធ ១២រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ រហូតដល់ថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹង ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩** រៀងរាល់ម៉ោងធ្វើការ។

២.ចំពោះសេចក្តីសម្រេចអនុញ្ញាតឱ្យបេក្ខជនចូលរួមប្រឡង កាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡង គណៈកម្មការរៀបចំការប្រឡង នឹងជូនដំណឹងបន្ទាប់ពីបិទការតវ៉ា **នៅថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩** តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ទាំងអស់ដែលបានដាក់ពាក្យប្រឡងចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័នទាំង៤ ខាងលើជ្រាបជាព័ត៌មាន៕

※ ព័ត៌មានលម្អិត សូមធ្វើការទំនាក់ទំនងមកក្រសួងមុខងារសាធារណៈ ដែលមានទីតាំងស្ថិតនៅ ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ (ទល់មុខវត្តអង្គតាមិញ)។

**រដ្ឋលេខាធិការនិងជា**
**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**ខៀវ ច័ន្ទប៊ុនធឿន**

**ចម្លងជូន៖**
-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា
ព្រឹទ្ធសភានិងអធិការកិច្ច
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
" ដើម្បីជូនជ្រាប និងសហការណ៍ផ្សព្វផ្សាយ "
-ឯកសារ កាលប្បវត្តិ